# សេចក្តីប្រកាសព័ត៌មានរវាងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង អង្គការសុខភាពពិភពលោក

30 April 2009

**សំរាប់ការផ្សព្វផ្សាយជាបន្ទាន់**

ភ្នំពេញថ្ងៃទី ៣០ មេសា ឆ្នាំ ២០០៩ ម៉ោង ៥ល្ងាចៈ ក្រសួងសុខាភិបាលនៃប្រទេសកម្ពុជា និងអង្គការសុខភាពពិភពលោក បាននិយាយថា **ប្រទេសកម្ពុជាស្ថិតនៅក្នុងស្ថានភាពនៃប្រុងប្រយ័ត្នខ្ពស់ និងត្រៀមខ្លួនជាស្រេចដើម្បីអនុវត្តនូវផែនការត្រៀមលក្ខណៈទប់ទល់ទៅនឹង ការរាលដាលជាសាកល** ។

ដោយអង្គការសខុភាពពិភពលោកកាលពីម្សិលមិញបានដាក់នូវការប្រុងប្រយ័ត្នចំពោះការរាលដាលជាសាកលថាស្ថិតនៅក្នុងដំណាក់កាលទី ៥ នៅក្នុងចំណោមដំណាក់កាលអន្តរជាតិចំនួន ៦ នោះ ឥឡូវនេះ ប្រទេសកម្ពុជាកំពុងតែបង្កើននូវកិច្ចប្រឹងប្រែងរបស់ខ្លួននៅក្នុងការ ត្រៀមលក្ខណៈដើម្បីទប់ទល់ទៅនឹងការរាលជាសាកល ។

មកទល់ពេលនេះមិនទាន់មានករណីគ្រុនផ្តាសាយ **H1N1** (ជ្រូក) ដែលត្រូវបានរាយការណ៍នៅក្នុងប្រទេសក្តុជាទេ ។ មន្ត្រីកំពុងតាមដាម ជំងឺនេះយ៉ាងជិតដិត ដើម្បីស្វែងរកនូវការរាតត្បាតខុសផ្លែកពីធម្មតានៃជំងឺដែលមានអាការៈរោគដូចគ្នានឹងជំងឺគ្រុនផ្តាសាយ និងការរលាក ទងសួតធ្ងន់ធ្ងរ ។

ស្របជាមួយនឹងផែនការផែនការជាតិរបស់រាជរដ្ឋាភិបាល ស្តីអំពីការត្រៀមលក្ខណៈទប់ទល់នឹងជំងឺគ្រុនផ្តាសាយ ថ្ងៃនេះ ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក បានធ្វើការប្រជុំការងារបច្ចេកទេសរួមគ្នាសំរាប់រដ្ឋាភិបាល ទីភ្នាក់ងារសហប្រជាជាតិ ម្ចាស់ជំនួយ អង្គការ ក្រៅរដ្ឋាភិបាល និងដៃគូដទៃទៀត ដើម្បីធានាថា មានការជូនដំណឹង និងការសំរបសំរួមត្រឹមត្រូវ នៅក្នុងចំណោមវិស័យទាំងអស់ ។

តំណាងមកពីក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិគ្របលគ្រងគ្រោះមហន្តរាយ ទីភ្នាក់ងារអន្តរជាតិ កាកបាទក្រហមកម្ពុជា និងអង្គការ MEDICAM ក៏បានជួមគ្នាផងដែរ ដើម្បីបង្កើតឡើងនូវក្រុមការងារផ្សព្វផ្សាយអំពីការរាលដាលជាសាកល ដើម្បីសំរបសំរួលនូវសារសំរាប់ សាធារណៈជនស្តីអំពីអនាម័យ ។

ក្រសួងសុខាភិបាល បានចេញនូវការណែនាំសុខភាពជូនសាធារណៈជនអំពីៈ

**របៀបការពារខ្លួនអ្នក និងអ្នកដទៃទៀត ពីជំងឺគ្រុនផ្តាសាយជូក H1N1**

- គ្របមាត់របស់អ្នកដោយប្រើក្រដាសអនាម័យ ឬកែងដៃរបស់អ្នក នៅក្នុងពេលដែលអ្នកក្អក និងកណ្តាស
- លាងសំអាតដៃរបស់អ្នកជារឿយៗ ដោយប្រើសាប៊ូ
- កុំស្តោះទឹកមាត់នៅក្នុងទីសាធារណៈ

គ្រប់សមាជិកទាំងអស់នៃសាធារណៈជន ដែលបានធ្វើដំណើរទៅកាន់ទីកន្លែងដែលមានការឆ្លងរោគ ឬនរណាដែលមានការប៉ះពាល់ជាមួយ ជនដែលមកពីកន្លែងដែលមានការឆ្លងរោគ និងជនដែលមានអាការៈរោគដូចតទៅនេះ (គ្រុនក្តៅ ឈឺក្បាល រហិតរហៃក្នុងខ្លួន ក្អក ឈឺបំពង់ក ហៀរសំបោរ រកកលចង់ក្អួត ក្អួត និងការរាគរូស) ត្រូវស្នាក់នៅក្នុងផ្ទះ និងត្រូវហៅទូរស័ព្ទទាន់សភាពការដែលមានលេខ: **០១២ ៤៨៩ ៩៨១** និង **០៨៩ ៦៦៩ ៥៦៧** ។

ក្រសួងសុខាភិបាលនឹងបន្តចេញនូវរបាយការណ៍ទៀតទាត់ស្តីអំពីស្ថានភាពជំងឺនៅក្នុងវេបសាយធ៏របស់ខ្លួន www.cdcmoh.gov.kh ។ សូមមេត្តាចូលនៅពិនិត្យនៅក្នុងវេបសាយធ៏របស់ខ្លួននេះអោយបានទៀតទាត់ ដើម្បីអាននូវពតិមានទាន់សភាពការណ៍អំពីស្ថានភាពជំងឺ ។

---

_

For more information, please contact:


**Ministry of Health**
Dr Sok Touch: Telephone +855 012 856 848
Dr Ly Sovann: Telephone +855 012 825 424

**World Health Organization**
Dr Mike O’Leary: Telephone +855 023 216 610